# ឧបសម្ព័ន្ធ ៤

# តារាងសន្យាសេវាកម្មតាមវិស័យ

## ផ្នែក "ក"

## កញ្ចប់សន្យាសេវាកម្មរបស់ភាគីចិន
## សម្រាប់ផ្តល់ជូនភាគីកម្ពុជា

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | |
|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | |
| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |

## I. ការសន្យាទូទៅ[1]

| | | | |
|---|---|---|---|
| គ្រប់វិស័យដែលមាននៅក្នុងតារាងសន្យានេះ[2] | (១) (២) (៣) (៤)៖ មិនសន្យាចំពោះសេវាកម្មសង្គមដែលបង្កើតឡើង ឬរក្សាទុកសម្រាប់គោលបំណងសាធារណៈ។ សេវាសង្គមទាំងនេះអាចជាកម្មវត្ថុនៃការគ្រប់គ្រងផ្តាច់មុខរបស់សាធារណៈ ឬជាកម្មវត្ថុនៃសិទ្ធិផ្តាច់មុខដែលផ្តល់ឱ្យប្រតិបត្តិករឯកជន។<br><br>ភាគីចិនរក្សាសិទ្ធិចំពោះភាគីមួយទៀតដើម្បី អនុម័តឬរក្សាទុកវិធានការណាមួយដែលខ្លួនចាត់ទុកថាចាំបាច់សម្រាប់ការពារផលប្រយោជន៍ជាសារវន្តផ្នែកសន្តិសុខ ដូចជាការពិនិត្យលើការស្នើសុំវិនិយោគជាដើម ក្នុងករណីដែលភាគីនោះរក្សាសិទ្ធិដើម្បីអនុម័តឬរក្សាទុកវិធានការមួយដែលខ្លួនចាត់ទុកថាចាំបាច់សម្រាប់ការពារផលប្រយោជន៍ផ្នែកសន្តិសុខនៅក្នុងតារាងសន្យាតាមវិស័យឬនៅក្នុងវិធានបដិលោមរបស់ខ្លួន។ | (១) (២) (៣) (៤)៖ មិនសន្យាចំពោះសេវាសង្គមដែលបង្កើតឡើង ឬរក្សាទុកសម្រាប់គោលបំណងសាធារណៈ។ សេវាកម្ម សង្គមទាំងនេះអាចជាកម្មវត្ថុនៃការគ្រប់គ្រងផ្តាច់មុខរបស់សាធារណៈ ឬជាកម្មវត្ថុនៃសិទ្ធិផ្តាច់មុខដែលផ្តល់ឱ្យប្រតិបត្តិករឯកជន។<br><br>ភាគីចិនរក្សាសិទ្ធិចំពោះភាគីមួយទៀតដើម្បី អនុម័តឬរក្សាទុកវិធានការណាមួយដែលខ្លួនចាត់ទុកថាចាំបាច់សម្រាប់ការពារផលប្រយោជន៍ជាសារវន្តផ្នែកសន្តិសុខ ដូចជាការស្នើសុំវិនិយោគជាដើម ក្នុងករណីដែលភាគីនោះរក្សាសិទ្ធិដើម្បីអនុម័តឬរក្សាទុកវិធានការមួយដែលខ្លួនចាត់ទុកថាចាំបាច់សម្រាប់ការពារផលប្រយោជន៍ផ្នែក | |

[1] នៅក្នុងតារាងសន្យាតាមវិស័យនេះ ពាក្យថា«បរទេស» ទាំងនៅក្នុងតារាងសន្យាតាមវិស័យនិងតារាងសន្យាទូទៅ សំដៅផងដល់«ជនជាតិកម្ពុជា»។

[2] ករណីដែលការសន្យាត្រូវបានបង្កើតឡើងទាក់ទងនឹងពាក្យថា«សហគ្រាស/ក្រុមហ៊ុនបុគ្រសម្ព័ន្ធដែលបរទេសជាម្ចាស់កម្មសិទ្ធិទាំងស្រុង» មានន័យថាកម្មសិទ្ធិភាគតិចឬច្រើនរបស់បរទេសក៏ត្រូវបានអនុញ្ញាតផងដែរ លើកលែងតែមានការតម្រូវពិសេសក្រោមច្បាប់និងបទប្បញ្ញត្តិរបស់ភាគីចិន។ ករណីការសន្យាត្រូវបានធ្វើឡើងទាក់ទងនឹងពាក្យថា«កម្មសិទ្ធិភាគច្រើនដោយបរទេសត្រូវបានអនុញ្ញាត» មានន័យថាកម្មសិទ្ធិភាគតិចដោយបរទេសក៏ត្រូវបានអនុញ្ញាតផងដែរ ប៉ុន្តែកម្មសិទ្ធិភាគច្រើនដោយបរទេសមិនត្រូវបានប្រើសំដៅន័យថាកម្មសិទ្ធិទាំងស្រុងដោយបរទេសនោះទេ។

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | |
|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | |
| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
| | (៣) "សហគ្រាសវិនិយោគ/ក្រុមហ៊ុនបរទេស" នៅក្នុងតារាងសន្យានេះ សំដៅដល់សហគ្រាសទាំងឡាយដែលត្រូវបានវិនិយោគមួយផ្នែក ឬទាំងស្រុងដោយវិនិយោគិនបរទេស ហើយត្រូវបានចុះបញ្ជីនៅក្នុងដែនដីរបស់ភាគីចិន ដែលស្ថិតក្រោម*ច្បាប់ស្ដីពីការវិនិយោគបរទេសនៃសាធារណរដ្ឋប្រជាមានិតចិន (ឆ្នាំ២០១៩)* ដោយគោរពតាមខចែងនិងលក្ខខណ្ឌកំណត់តាមវិស័យនៅក្នុងតារាងសន្យានេះ។<br><br>លើកលែងតែមានកំណត់ក្នុង វិស័យ/អនុវិស័យជាក់លាក់ នៃការបង្កើតសាខាដោយសហគ្រាសបរទេសគឺមិនសន្យាដោយសារតែច្បាប់ និងបទប្បញ្ញត្តិស្ដីពីសាខាសហគ្រាសបរទេសកំពុងតែត្រូវបានរៀបចំតាក់តែងឡើង។<br><br>ការិយាល័យតំណាងនៃសហគ្រាសបរទេសត្រូវបានអនុញ្ញាតឱ្យបង្កើតឡើងនៅប្រទេសចិន ប៉ុន្តែសហគ្រាសទាំងនេះមិនត្រូវចូលរួមធ្វើសកម្មភាព | សន្តិសុខនៅក្នុងតារាងសន្យាតាមវិស័យឬនៅក្នុងវិធានបដិលោមរបស់ខ្លួន។<br><br>(៣) មិនសន្យាចំពោះគ្រប់ឧបត្ថម្ភធនដល់អ្នកផ្គត់ផ្គង់សេវាកម្មក្នុងស្រុក លើកលែងតែឧបត្ថម្ភធនទាំងឡាយដែលសន្យាដោយភាគីចិននៅក្រោមអង្គការពាណិជ្ជកម្មពិភពលោក។ | |

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | |
|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | |
| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
| | ក្នុងការរកប្រាក់ចំណេញណាមួយឡើយ លើកលែងតែការិយាល័យតំណាងស្ថិតក្រោម CPC ៨៦១ ៨៦២ ៨៦៣ ៨៦៥ នៅក្នុងតារាងសន្យាតាមវិស័យ។<br><br>ដីធ្លីនៅក្នុងសាធារណរដ្ឋប្រជាមានិតចិន គឺជាកម្មសិទ្ធិរបស់រដ្ឋ។ ការប្រើប្រាស់ដីដោយ សហគ្រាសនិងឯកត្តបុគ្គលត្រូវគោរពតាមរយៈពេលកំណត់អតិបរមាដូចខាងក្រោម៖<br><br>(ក) ៧០ឆ្នាំសម្រាប់គោលបំណងលំនៅដ្ឋាន;<br>(ខ) ៥០ឆ្នាំសម្រាប់គោលបំណងឧស្សាហកម្ម;<br>(គ) ៥០ឆ្នាំសម្រាប់គោលបំណងអប់រំ វិទ្យាសាស្ត្រ វប្បធម៌ សុខភាពសាធារណៈ និងអប់រំកាយ;<br>(ឃ) ៤០ឆ្នាំសម្រាប់គោលបំណងពាណិជ្ជកម្ម ទេសចរណ៍ និងការកំសាន្ត;<br>(ង) ៥០ឆ្នាំសម្រាប់ការប្រើប្រាស់ទូលំទូលាយ ឬសម្រាប់គោលបំណងផ្សេងៗទៀត<br><br>(៤) (ក) អ្នកគ្រប់គ្រង នាយកប្រតិបត្តិ និងអ្នកឯកទេសត្រូវបានកំណត់ជានិយោជិតជាន់ | (៤) មិនសន្យាលើកលែងតែខចែង លក្ខខណ្ឌការកំណត់ ឬគុណវុឌ្ឍិពាក់ព័ន្ធនឹងការចូល | |

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | |
|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | |
| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
| | ខ្ពស់នៃសាជីវកម្មរបស់ភាគីមួយដែលបានបង្កើតការិយាល័យតំណាង សាខាឬ ក្រុមហ៊ុនបុត្រសម្ព័ន្ធនៅក្នុងដែនដីនៃសាធារណរដ្ឋប្រជាមានិតចិន ដែលបានបម្លាស់ទីបណ្តោះអាសន្នជាបុគ្គលដែលត្រូវផ្លាស់ប្តូរក្នុងសាជីវកម្មតែមួយ ត្រូវបានអនុញ្ញាតឱ្យចូលមកស្នាក់នៅលើកដំបូងរយៈពេលបីឆ្នាំ;<br>(ខ) អ្នកគ្រប់គ្រង នាយកប្រតិបត្តិ និងអ្នក ឯកទេសដែលកំណត់ជានិយោជិតជាន់ខ្ពស់នៃសាជីវកម្មរបស់ភាគី ដែលពាក់ព័ន្ធនឹងសហគ្រាសវិនិយោគបរទេសនៅក្នុងដែនដីនៃសាធារណរដ្ឋប្រជាមានិតចិនដើម្បីធ្វើពាណិជ្ជកម្ម ត្រូវបានផ្តល់ការអនុញ្ញាតឱ្យស្នាក់នៅរយៈពេលវែងដូចមានកំណត់ក្នុងខចែងនៃកិច្ចសន្យាពាក់ព័ន្ធ ឬការស្នាក់នៅដំបូងរយៈពេលបីឆ្នាំ ឬរយៈពេលណាមួយដែលខ្លីជាងនេះ។<br>(គ) អ្នកលក់សេវាកម្ម - បុគ្គលដែលមិនមានទីតាំងនៅក្នុងដែនដីនៃសាធារណរដ្ឋប្រជាមានិតចិន និងមិនទទួលបានលាភការពីប្រភពមួយដែលស្ថិតនៅក្នុងប្រទេសចិន ហើយធ្វើសកម្មភាពទាក់ទងនឹងការតំណាង | និងការស្នាក់នៅបណ្តោះអាសន្នរបស់រូបវន្តបុគ្គលដែលស្ថិតក្នុងជំពូកនានាដែលមានកំណត់នៅក្នុងតារាងជួរឈរស្តីពីការបើកទីផ្សារ។ | |

| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
|---|---|---|---|
| | អ្នកផ្គត់ផ្គង់សេវាកម្មក្នុងគោលបំណងចរចាលក់សេវាកម្មនៃអ្នកផ្គត់ផ្គង់ សេវាកម្មនោះ ក្នុងករណីដែល៖<br>(i)ការលក់ទាំងនោះមិនបានលក់ផ្ទាល់ឱ្យទៅសាធារណជន និង<br>(ii)អ្នកលក់នោះមិនបានពាក់ព័ន្ធនឹងការផ្គង់ផ្គង់សេវាកម្ម៖ ការចូលមកក្នុងប្រទេសសម្រាប់អ្នកលក់នោះមានរយៈពេលកំណត់ ៩០ថ្ងៃ។<br>(ឃ) អ្នកផ្គត់ផ្គង់សេវាកម្មតាមកិច្ចសន្យា (CSS) ៖ រូបវន្តបុគ្គលបរទេសដែលចូលមកក្នុងដែនដីប្រទេសចិនជាបណ្តោះអាសន្នដើម្បីអនុវត្តកិច្ចសន្យាអនុលោមតាមកិច្ចសន្យារវាងនិយោជករបស់រូបវន្តបុគ្គលនោះ និងអ្នកប្រើប្រាស់សេវាកម្មនៅប្រទេសចិន។ និយោជករបស់រូបវន្តបុគ្គលនោះត្រូវតែជាក្រុមហ៊ុន/ដៃគូ/ក្រុមហ៊ុននៃភាគីផ្សេងទៀតដែលគ្មានវត្តមានពាណិជ្ជកម្មនៅក្នុងដែនដីប្រទេសចិន។ CSS ទទួលលាភការពីនិយោជករបស់ខ្លួនខណៈ ពេលបម្រើការងារនៅបរទេស និងមានគុណវុឌ្ឍិវិជ្ជាជីវៈសមស្របផ្នែកអប់រំនិងបច្ចេកទេស | | |

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | |
|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | |
| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
| | ទាក់ទងនឹងសេវាកម្មដែលត្រូវបម្រើ។ រយៈពេលស្នាក់នៅរបស់អ្នកផ្គត់ផ្គង់សេវាកម្មតាមកិច្ចសន្យាត្រូវគោរពតាម រយៈពេលដែលមានកំណត់ក្នុងកិច្ចសន្យា តែមិនត្រូវមានរយៈពេលលើសពីមួយឆ្នាំ។ អ្នកផ្គត់ផ្គង់សេវាកម្មទាំងនេះមិនអាចបម្រើសេវាកម្មដែលមិនពាក់ព័ន្ធនឹងសកម្មភាពសេវាកម្មដែលមានកំណត់នៅក្នុងកិច្ចសន្យា បានឡើយ។ សេវាកម្មផ្តល់ដោយ CSS ត្រូវបានកម្រិតត្រឹមវិស័យជាក់លាក់ ដូចខាងក្រោម៖<br>១. សេវាកម្មគណនេយ្យ<br>២. សេវាកម្មវេជ្ជសាស្ត្រនិងទន្តសាស្ត្រ<br>៣.សេវាកម្មស្ថាបត្យកម្ម<br>៤. សេវាកម្មវិស្វកម្ម<br>៥. សេវាកម្មធ្វើផែនការនគរូបនីយកម្ម (លើកលែងតែ ការធ្វើផែនការនគរូបនីយកម្មទូទៅ)<br>៦. សេវាកម្មកុំព្យូទ័រនិងសេវាកម្មពាក់ព័ន្ធកុំព្យូទ័រ<br>៧. សេវាកម្មសំណង់និងសេវាកម្មវិស្វកម្មពាក់ព័ន្ធសំណង់ | | |

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | |
|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | |
| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
| | ៨. សេវាកម្មអប់រំ៖ CSS ត្រូវមានសញ្ញាបត្របរិញ្ញាបត្រឬសញ្ញាបត្រកម្រិតខ្ពស់ជាងនេះ និងទទួលបានមុខងារវិជ្ជាជីវៈឬវិញ្ញាបនបត្រសមស្រប ព្រមទាំងមានបទពិសោធន៍ការងារវិជ្ជាជីវៈយ៉ាងតិច ២ឆ្នាំ។ ភាគីចិនដែលពាក់ព័ន្ធក្នុងកិច្ចសន្យាត្រូវជានីតិបុគ្គលដែលមានមុខងារផ្តល់សេវាកម្មអប់រំ។<br>៩. សេវាកម្មទេសចរណ៍<br>(ង) អ្នកតម្លើងនិងអ្នកបម្រើសេវាកម្មផ្សេងៗ៖ អ្នកឯកទេសដែលមានគុណវុឌ្ឍិផ្គត់ផ្គង់សេវាកម្មតម្លើងឬសេវាកម្មថែទាំសម្រាប់គ្រឿងម៉ាស៊ីន ឬបរិក្ខារឧស្សាហកម្ម។ ការផ្គត់ផ្គង់សេវាកម្មនោះត្រូវប្រព្រឹត្តទៅដោយឈរលើមូលដ្ឋាននៃកិច្ចសន្យាឬការគិតកម្រៃ (កិច្ចសន្យាតម្លើង/ថែទាំ) រវាងអ្នកបង្កើតគ្រឿងម៉ាស៊ីនឬបរិក្ខា និងម្ចាស់នៃគ្រឿងម៉ាស៊ីនឬបរិក្ខានោះ ដោយអ្នកទាំងពីរជានីតិបុគ្គល។<br><br>រយៈពេលនៃការស្នាក់អាស្រ័យនៅរបស់អ្នកតម្លើងនិងអ្នកបម្រើសេវាកម្មត្រូវគោរពតាមរយៈពេល | | |

## តារាងសន្យាតាមវិស័យរបស់ភាគីចិន

ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម

| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
|---|---|---|---|
| | កំណត់ក្នុងកិច្ចសន្យា ប៉ុន្តែរយៈពេលនេះមិនត្រូវលើសពី ៣ខែឡើយ។ អ្នកតម្លើងនិងអ្នកបម្រើសេវាកម្មមិនអាចអនុវត្តសេវាកម្មដែលមិនមែនជាកម្មវត្ថុនៃកិច្ចសន្យា ហើយត្រូវមានគុណវុឌ្ឍិវិជ្ជាជីវៈសមស្របពាក់ព័ន្ធនឹងសេវាកម្មដែលត្រូវអនុវត្ត។ | | |

| II. ការសន្យាតាមវិស័យ | | | |
|---|---|---|---|
| **១. សេវាកម្មធុរកិច្ច** | | | |
| A. សេវាកម្មវិជ្ជាជីវៈ<br><br>(a) សេវាកម្មផ្នែកច្បាប់<br>(CPC ៨៦១, មិនរាប់បញ្ចូលការអនុវត្តច្បាប់របស់ប្រទេសចិន) | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br><br>(៣) ក្រុមហ៊ុនច្បាប់របស់បរទេសអាចផ្តល់សេវាកម្មផ្នែកច្បាប់តែនៅក្នុងទម្រង់ជាការិយាល័យតំណាងប៉ុណ្ណោះ។ ការិយាល័យតំណាងអាចចូលរួមក្នុងសកម្មភាពរកប្រាក់ចំណេញ។ វិសាលភាពអាជីវកម្មការិយាល័យតំណាងរបស់បរទេសមានដូចខាងក្រោម៖<br>(a) ផ្តល់ជូនអតិថិជននូវការពិគ្រោះយោបល់លើច្បាប់របស់ប្រទេស/តំបន់ដែលមេធាវីរបស់ | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br><br>(៣) អ្នកតំណាងទាំងអស់ត្រូវស្នាក់នៅប្រទេសចិន មិនតិចជាងប្រាំមួយខែ ជារៀងរាល់ឆ្នាំ។ ការិយាល័យតំណាងមិនត្រូវជួលមេធាវីដែលចុះបញ្ជីនិងមានសញ្ជាតិចិនឡើយ។ | ដោយយោងទៅតាមច្បាប់ បទប្បញ្ញត្តិនិងវិធានរបស់ប្រទេសចិនក្រុមហ៊ុនច្បាប់របស់បរទេសដែលបានបង្កើតការិយាល័យតំណាងរបស់ពួកគេនៅក្នុងតំបន់ពាណិជ្ជកម្មសេរីសាកល្បងចិន (សៀងហៃ)(FTZ) អាចចុះកិច្ចសន្យាជាមួយក្រុមហ៊ុនច្បាប់របស់ប្រទេសចិននៅក្នុង FTZ ។ ផ្អែកលើកិច្ចសន្យានេះ ក្រុមហ៊ុនច្បាប់របស់បរទេសនិងចិនទាំងនេះអាចបញ្ជូនមេធាវីរបស់ពួកគេទៅគ្នាទៅវិញទៅមក ដើម្បីធ្វើជាអ្នកប្រឹក្សាផ្នែកច្បាប់។ |

# តារាងសន្យាតាមវិស័យរបស់ភាគីចិន

ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម

| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
|---|---|---|---|
| | ក្រុមហ៊ុនផ្នែកច្បាប់ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការងារវិជ្ជាជីវៈមេធាវី និងអនុសញ្ញាអន្តរជាតិ និងទម្លាប់អន្តរជាតិ<br>(b) ដោះស្រាយការងារច្បាប់របស់ប្រទេស/តំបន់ដែលមេធាវីរបស់ក្រុមហ៊ុនច្បាប់ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការងារវិជ្ជាជីវៈមេធាវី នៅពេលអតិថិជនឬក្រុមហ៊ុនច្បាប់របស់ភាគីចិនប្រគល់កិច្ចការឱ្យក្រុមហ៊ុនច្បាប់របស់បរទេស<br>(c) ប្រគល់ការងារឱ្យក្រុមហ៊ុនច្បាប់របស់ភាគីចិន ដើម្បីដោះស្រាយការងារច្បាប់នៅប្រទេសចិន ក្នុងនាមតំណាងឱ្យអតិថិជនបរទេស<br>(d) ចុះកិច្ចសន្យា ដើម្បីរក្សាទំនាក់ទំនងការងាររយៈពេលវែងជាមួយក្រុមហ៊ុនច្បាប់របស់ភាគីចិនសម្រាប់កិច្ចការផ្នែកច្បាប់<br>(e) ផ្តល់ព័ត៌មានស្តីពីផលប៉ះពាល់នៃច្បាប់របស់ប្រទេសចិន។<br><br>ការប្រគល់ភារកិច្ចលើការងារច្បាប់ អនុញ្ញាតឱ្យការិយាល័យតំណាងរបស់បរទេសធ្វើការណែនាំដោយផ្ទាល់ដល់មេធាវីរបស់ក្រុមហ៊ុន | | ចំពោះការបញ្ជូនមេធាវី ដូចបានបញ្ជាក់ខាងលើ មានន័យថាក្រុមហ៊ុនច្បាប់របស់ប្រទេសចិនអាចបញ្ជូនមេធាវីរបស់ខ្លួនទៅឱ្យក្រុមហ៊ុនច្បាប់របស់បរទេស ដើម្បីដើរតួជាអ្នកប្រឹក្សាផ្នែកច្បាប់លើការ អនុវត្តច្បាប់នៃប្រទេសចិននិងច្បាប់អន្តរជាតិ ហើយក្រុមហ៊ុនច្បាប់របស់បរទេសអាចបញ្ជូនមេធាវីរបស់ពួកគេទៅឱ្យក្រុមហ៊ុនច្បាប់របស់ប្រទេសចិនដើម្បីដើរតួជាអ្នកប្រឹក្សាផ្នែកច្បាប់លើការអនុវត្តច្បាប់របស់បរទេសនិងច្បាប់អន្តរជាតិ។ ភាគីទាំងពីរអនុវត្តកិច្ចសហប្រតិបត្តិការក្នុងវិសាលភាពអាជីវកម្មរៀងៗខ្លួន។<br><br>អនុលោមតាមច្បាប់ បទប្បញ្ញត្តិនិងវិធានរបស់ប្រទេសចិន ក្រុមហ៊ុនបរទេសដែលបង្កើតការិយាល័យតំណាងរបស់ពួកគេនៅក្នុងតំបន់ពាណិជ្ជកម្មសេរីសាកល្បងចិន(សៀងហៃ)(FTZ) ត្រូវបានអនុញ្ញាតឱ្យបង្កើតសមាគមពាណិជ្ជកម្មជាមួយក្រុម |

| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
|---|---|---|---|
| | ច្បាប់របស់ភាគីចិនដែលទទួលបានការទុកចិត្ត ដូចដែលបានព្រមព្រៀងរវាងភាគីទាំងពីរ។ អ្នកតំណាងក្រុមហ៊ុនច្បាប់របស់បរទេសគឺជាមេធាវីដែលជាសមាជិកនៃ គណៈមេធាវីឬក្រុមអ្នកច្បាប់នៅបរទេស ហើយមានបទពិសោធន៍អនុវត្តនៅក្រៅប្រទេសចិន មិនតិចជាងពីរឆ្នាំ។ ប្រធានតំណាងគឺជាដៃគូឬមានឋានៈប្រហាក់ប្រហែល(ឧទាហរណ៍ សមាជិកនៃក្រុមហ៊ុនច្បាប់នៃក្រុមហ៊ុនសាជីវកម្មទទួលខុសត្រូវមានកម្រិត) នៃក្រុមហ៊ុនច្បាប់របស់បរទេស ហើយមានបទពិសោធន៍អនុវត្ត មិនតិចជាងបីឆ្នាំ នៅក្រៅប្រទេសចិន។<br><br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | ហ៊ុនផ្នែកច្បាប់របស់ប្រទេសចិននៅ FTZ សៀងហៃ។ ក្នុងអាណត្តិនៃសមាគមពាណិជ្ជកម្ម ក្រុមហ៊ុនច្បាប់ទាំងពីរដែលមកពី ភាគីទាំងសងខាង មានភាពឯករាជ្យស្របច្បាប់ ឈ្មោះ ប្រតិបត្តិការហិរញ្ញវត្ថុ និងការទទួលខុសត្រូវរដ្ឋប្បវេណីដោយឯករាជ្យ។ អតិថិជន នៃសមាគមពាណិជ្ជកម្មមិនត្រូវបានដាក់កម្រិតនៅក្នុង FTZ សៀងហៃឡើយ។ មេធាវីបរទេសនៅក្នុងសមាគមពាណិជ្ជកម្មប្រភេទនេះមិនត្រូវបានអនុញ្ញាតឱ្យអនុវត្តច្បាប់របស់ប្រទេសចិនទេ។ |
| (b) គណនេយ្យ, សវនកម្ម និង សេវាកម្មកាន់បញ្ជីគណនេយ្យ (CPC ៨៦២) | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br><br>(៣) ក្រុមហ៊ុនគណនេយ្យសហកម្មសិទ្ធិឬក្រុមហ៊ុនគណនេយ្យដែលមានឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br><br>(៣) ពុំមានការរឹតត្បិត | - ក្រុមហ៊ុនគណនេយ្យរបស់បរទេសត្រូវបានអនុញ្ញាតឱ្យចងសម្ព័ន្ធ ជាមួយក្រុមហ៊ុនរបស់ភាគីចិន និងចុះកិច្ចសន្យាជាមួយក្រុមហ៊ុនចងសម្ព័ន្ធ |

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | |
|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | |
| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
| | ត្រូវបានកំណត់ចំពោះគណនេយ្យករសាធារណៈមានវិញ្ញាបនបត្រ (CPAs) ដែលទទួលបានអាជ្ញាបណ្ណពីអាជ្ញាធរចិន។<br><br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | ផ្សេងៗទៀត ដែលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។<br>- ការចេញអាជ្ញាបណ្ណដល់ជនបរទេសដែលបានប្រឡងជាប់ CPA ថ្នាក់ជាតិរបស់ប្រទេសចិន នឹង ទទួលបានប្រព្រឹត្តិកម្មជាតិ។<br>- អ្នកដាក់ពាក្យស្នើសុំនឹងត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរ ពីលទ្ធផល មិនលើសពី ៣០ ថ្ងៃបន្ទាប់ពីការដាក់ពាក្យស្នើសុំរបស់ពួកគេ។<br>- ក្រុមហ៊ុនគណនេយ្យដែលផ្តល់សេវាកម្មនៅក្នុង CPC ៨៦២ អាចចូលរួមក្នុងការផ្តល់សេវាកម្មប្រឹក្សាយោបល់ពន្ធនិងការគ្រប់គ្រង។ ក្រុមហ៊ុនប្រភេទនេះនឹងមិនស្ថិតក្នុងលក្ខខណ្ឌតម្រូវក្នុងទម្រង់នៃការបង្កើតនៅក្នុង CPC ៨៦៥ និង ៨៦៣០ ឡើយ។ |
| (c) សេវាកម្មពន្ធដារ (CPC ៨៦៣០) | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) ក្រុមហ៊ុនបុគ្រសម្ព័ន្ធកម្មសិទ្ធិបរទេសទាំងស្រុងត្រូវបានអនុញ្ញាត។ | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) ពុំមានការរឹតត្បិត | |

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | |
|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | |
| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
| | (៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |
| (d) សេវាកម្មស្ថាបត្យកម្ម (CPC ៨៦៧១)<br><br>(e) សេវាកម្មវិស្វកម្ម (CPC ៨៦៧២)<br><br>(f) សេវាកម្មវិស្វកម្មចម្រុះ (CPC ៨៦៧៣)<br><br>(g) សេវាកម្មរៀបចំនគរូបនីយកម្ម (លើកលែងតែការរៀបចំផែនការនគរូបនីយកម្មទូទៅ) (CPC ៨៦៧៤) | (១) ពុំមានការរឹតត្បិត សម្រាប់គម្រោងរចនាម៉ូត។ តម្រូវឱ្យមានកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នវិជ្ជាជីវៈរបស់ប្រទេសចិន លើកលែងតែគម្រោងរចនាម៉ូត។<br><br>(២) ពុំមានការរឹតត្បិត<br><br>(៣) សហគ្រាសបុត្រសម្ព័ន្ធកម្មសិទ្ធិបរទេសទាំងស្រុងត្រូវបានអនុញ្ញាត។<br><br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (១) ពុំមានការរឹតត្បិត<br><br>(២) ពុំមានការរឹតត្បិត<br><br>(៣) ពុំមានការរឹតត្បិត<br><br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |
| (h) សេវាកម្មវេជ្ជសាស្ត្រនិងទន្តសាស្ត្រ | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br><br>(៣) អ្នកផ្គត់ផ្គង់សេវាកម្មបរទេសត្រូវបានអនុញ្ញាតឱ្យបង្កើតមន្ទីរពេទ្យឬគ្លីនិកដែលវិនិយោគដោយផ្នែករបស់បរទេស ជាសហកម្មសិទ្ធិជាមួយវិនិយោគិន | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br><br>(៣) វេជ្ជបណ្ឌិតនិងបុគ្គលិកវេជ្ជសាស្ត្រភាគច្រើនរបស់មន្ទីរពេទ្យនិងគ្លីនិកដែលមានវិនិយោគ | |

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | |
|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | |
| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
| | ចិន ស្របទៅតាមកម្រិតបរិមាណតម្រូវការរបស់ប្រទេសចិន ដោយភាពជាម្ចាស់កម្មសិទ្ធិមួយភាគធំជារបស់ជនបរទេស ត្រូវបានអនុញ្ញាត។<br><br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ និងក្នុងករណីដូចខាងក្រោម៖ វេជ្ជបណ្ឌិតបរទេសដែលមានវិញ្ញាបនបត្រជំនាញចេញដោយប្រទេសកំណើតរបស់ខ្លួន ត្រូវបានអនុញ្ញាតឱ្យផ្តល់សេវាកម្មវេជ្ជសាស្ត្ររយៈពេលខ្លីនៅក្នុងប្រទេសចិន បន្ទាប់ពីពួកគេទទួលបានអាជ្ញាបណ្ណពីអាជ្ញាធរសុខាភិបាល។ លក្ខខណ្ឌនៃសេវាកម្មអាចមានរយៈពេលរហូតដល់ ៦ ខែនិងអាចពន្យារដល់ ១ឆ្នាំ។ | ដោយផ្នែករបស់បរទេស ត្រូវតែជាជនជាតិចិន។<br><br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |
| B. សេវាកម្មកុំព្យូទ័រ និងសេវាកម្ម ពាក់ព័ន្ធកុំព្យូទ័រ (សេវាកម្មកុំព្យូទ័រនិងសេវាកម្មពាក់ព័ន្ធកុំព្យូទ័រមិនរាប់បញ្ចូលសកម្មភាពសេដ្ឋកិច្ចដែលរួមមាន សេវាកម្មបង្កើតខ្លឹមសារដែលត្រូវការកុំព្យូទ័រ និងសេវាកម្មពាក់ព័ន្ធកុំព្យូទ័រ | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) ពុំមានការរឹតត្បិត<br><br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) ពុំមានការរឹតត្បិត<br><br>(៤) ត្រូវមានគុណវុឌ្ឍិដូចខាងក្រោម៖ វិស្វករដែលត្រូវបានទទួលស្គាល់ឬបុគ្គលិកដែលមានសញ្ញាបត្របរិញ្ញាបត្រ (ឬសញ្ញាបត្រកម្រិតខ្ពស់ជាងនេះ) និងមានបទពិសោធន៍ ៣ ឆ្នាំលើមុខជំនាញទាំងនេះ។ | |

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | |
|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | |
| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
| ជាមធ្យោបាយផ្គត់ផ្គង់ឡើយ)<br>(a) សេវាកម្មពិគ្រោះយោបល់ទាក់ទងនឹងការដំឡើងផ្នែករឹងរបស់កុំព្យូទ័រ (CPC ៨៤១) | | | |
| (b) សេវាកម្មអនុវត្តន៍កម្មវិធីកុំព្យូទ័រ (CPC ៨៤២)<br><br>(c) សេវាកម្មដំណើរការទិន្នន័យ (CPC ៨៤៣)<br>-សេវាកម្មបញ្ចូលទិន្នន័យ (CPC ៨៤៣១) | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) សហគ្រាសកម្មសិទ្ធិបរទេសទាំងស្រុងត្រូវបានអនុញ្ញាត។<br><br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) ពុំមានការរឹតត្បិត<br><br>(៤) ត្រូវមានគុណវុឌ្ឍិដូចខាងក្រោម៖ វិស្វករដែលត្រូវបានទទួលស្គាល់ឬបុគ្គលិកដែលមានសញ្ញាបត្របរិញ្ញាបត្រ (ឬសញ្ញាបត្រ កម្រិតខ្ពស់ជាងនេះ) និងមានបទពិសោធន៍ ៣ ឆ្នាំលើមុខជំនាញទាំងនេះ។ | |
| -សេវាកម្មដំណើរការ និងតារាងទិន្នន័យ (CPC ៨៤៣២)<br><br>-សេវាកម្មបែងចែកការងារក្នុងពេលតែមួយ ក្នុងប្រព័ន្ធកុំព្យូទ័រ | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) ពុំមានការរឹតត្បិត | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) ពុំមានការរឹតត្បិត | |

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | |
|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | |
| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
| (Time-sharing services)<br>(CPC ៨៤៣៣) | (៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (៤) ត្រូវមានគុណវុឌ្ឍិ ដូចខាងក្រោម៖ វិស្វករដែលត្រូវបានទទួលស្គាល់ឬបុគ្គលិកដែលមានសញ្ញាបត្របរិញ្ញាបត្រ (សញ្ញាបត្រកម្រិតខ្ពស់ជាងនេះ) និងមានបទពិសោធន៍ ៣ ឆ្នាំលើមុខជំនាញទាំងនេះ។ | |
| -សេវាថែទាំនិងជួសជុលគ្រឿងម៉ាស៊ីននិងសម្ភារៈការិយាល័យ រួមមាន កុំព្យូទ័រ (CPC ៨៤៥ និង ៨៨៦) | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣)<br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) ពុំមានការរឹតត្បិត<br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |
| D. សេវាកម្មអចលនទ្រព្យ<br>(a) សេវាកម្មអចលនទ្រព្យទាក់ទងនឹងទ្រព្យកម្មសិទ្ធិផ្ទាល់ឬជួលបន្ត (CPC ៨២១)<br>(b) សេវាកម្មអចលនទ្រព្យ លើមូលដ្ឋានគិតកម្រៃឬកិច្ចសន្យា (CPC ៨២២) | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) សហគ្រាសកម្មសិទ្ធិបរទេសទាំងស្រុងត្រូវបានអនុញ្ញាត។<br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) ពុំមានការរឹតត្បិត<br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | |
|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | |
| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
| E. សេវាកម្មជួល (CPC ៨៣១, ៨៣២) ដោយមិនរាប់បញ្ចូល (CPC ៨៣២០២) | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) សហគ្រាសកម្មសិទ្ធិបរទេសទាំងស្រុងត្រូវបានអនុញ្ញាត។ អ្នកផ្គត់ផ្គង់សេវាកម្មបរទេសត្រូវមានទ្រព្យសកម្មសកលចំនួន ៥ លានដុល្លារអាមេរិក។<br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) សហគ្រាសកម្មសិទ្ធិបរទេសទាំងស្រុងត្រូវបានអនុញ្ញាត។ អ្នកផ្គត់ផ្គង់សេវាកម្មបរទេសត្រូវមានទ្រព្យសកម្មសកលចំនួន ៥ លានដុល្លារអាមេរិក។<br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |
| F. សេវាកម្មធុរកិច្ចផ្សេងៗទៀត<br>(a) សេវាកម្មផ្សាយពាណិជ្ជកម្ម (CPC ៨៧១) | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) ពុំមានការរឹតត្បិត<br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) ពុំមានការរឹតត្បិត<br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |
| (b) សេវាកម្មស្រាវជ្រាវទីផ្សារ (CPC ៨៦៤០១, ត្រូវបានកំណត់ចំពោះសេវាកម្មស៊ើបអង្កេត ដែលត្រូវបានបង្កើត | (១) មិនសន្យា<br>(២) មិនសន្យា<br>(៣) មានតែសហគ្រាសវិនិយោគដោយផ្នែករបស់បរទេស ដែលមានកម្មសិទ្ធិភាគបរទេសភាគច្រើន | (១) មិនសន្យា<br>(២) មិនសន្យា<br>(៣) មិនសន្យា | |

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | |
|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | |
| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
| ឡើងដើម្បីធានាព័ត៌មានអំពីការរំពឹងទុកនិងដំណើរការផលិតផលរបស់ស្ថាប័នមួយនៅលើទីផ្សារតែប៉ុណ្ណោះ) | តែប៉ុណ្ណោះ ត្រូវបានអនុញ្ញាត។ ការធ្វើតេស្តតម្រូវការសេដ្ឋកិច្ច ត្រូវបានអនុវត្ត។<br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។។ លក្ខខណ្ឌតម្រូវសម្រាប់វត្តមានពាណិជ្ជកម្ម។ | (៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |
| (c) សេវាកម្មពិគ្រោះយោបល់ផ្នែកគ្រប់គ្រង (CPC ៨៦៥) | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣)<br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) ពុំមានការរឹតត្បិត<br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |
| (d) សេវាកម្មពាក់ព័ន្ធនឹងការពិគ្រោះយោបល់ផ្នែកគ្រប់គ្រង (សំដៅចំពោះតែអនុវិស័យខាងក្រោមប៉ុណ្ណោះ) | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) មានតែសហគ្រាសវិនិយោគដោយផ្នែករបស់បរទេស ដែលមានកម្មសិទ្ធិទុនបរទេសភាគច្រើនតែប៉ុណ្ណោះ ត្រូវបានអនុញ្ញាត។ ការធ្វើតេស្តតម្រូវការសេដ្ឋកិច្ច ត្រូវបានអនុវត្ត។ | (១) មិនសន្យា<br>(២) មិនសន្យា<br>(៣) មិនសន្យា | |

# តារាងសន្យាតាមវិស័យរបស់ភាគីចិន

ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម

| វិស័យ ឬ អនុវិស័យ | | ការរឹតត្បិតលើការបើកទីផ្សារ | | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
|---|---|---|---|---|---|
| - សេវាកម្មគ្រប់គ្រងគម្រោងក្រៅពីការសាងសង់(CPC ៨៦៦០១) | (៤) | មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (៤) | មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |
| (e) សេវាកម្មធ្វើតេស្ត និងវិភាគបច្ចេកទេស (CPC ៨៦៧៦) | (១)<br>(២)<br>(៣)<br><br><br><br><br><br><br><br><br><br><br><br>(៤) | ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត<br>អ្នកផ្គត់ផ្គង់សេវាកម្មបរទេសដែលបានចូលរួមនៅក្នុងសេវាកម្មត្រួតពិនិត្យនៅក្នុងប្រទេសកំណើតរបស់ពួកគេអស់រយៈពេលជាងបីឆ្នាំត្រូវបានអនុញ្ញាតឱ្យបង្កើតសហគ្រាសវិនិយោគដោយផ្នែករបស់បរទេសដែលមានភាគហ៊ុនមិនតិចជាង ៣៥០,០០០ដុល្លារអាមេរិកនៅក្នុងដើមទុនចុះបញ្ជី ដើម្បីធ្វើតេស្តបច្ចេកទេស វិភាគ និងត្រួតពិនិត្យទំនិញ ។<br>ក្រុមហ៊ុនបុត្រសម្ព័ន្ធកម្មសិទ្ធិទាំងស្រុងពីបរទេសត្រូវបានអនុញ្ញាត។<br><br>មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (១)<br>(២)<br>(៣)<br><br><br><br><br><br><br><br><br><br><br><br>(៤) | ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត<br><br><br><br><br><br><br><br><br><br><br><br>មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | | | |
|---|---|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | | | |
| វិស័យ ឬ អនុវិស័យ | | ការរឹតត្បិតលើការបើកទីផ្សារ | | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
| (f) សេវាកម្មបន្ទាប់បន្សំចំពោះរុក្ខាប្រមាញ់ (CPC ៨៨១៤) | (១) | ពុំមានការរឹតត្បិត | (១) | ពុំមានការរឹតត្បិត | |
| | (២) | ពុំមានការរឹតត្បិត | (២) | ពុំមានការរឹតត្បិត | |
| | (៣) | មានតែសហគ្រាសវិនិយោគដោយផ្នែករបស់បរទេស ដែលមានកម្មសិទ្ធិទុនបរទេសភាគច្រើនតែប៉ុណ្ណោះ ត្រូវបានអនុញ្ញាត។ | (៣) | ពុំមានការរឹតត្បិត | |
| | (៤) | មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (៤) | មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |
| (i) សេវាកម្មបន្ទាប់បន្សំចំពោះផលិតកម្ម (CPC ៨៨៤, ៨៨៥) លើកលែងតែ ៨៨៤៤២, និងមិនរាប់បញ្ចូលឧស្សាហកម្មដែលត្រូវបានហាមឃាត់ឬរឹតត្បិតសម្រាប់អ្នកផ្គត់ផ្គង់សេវាកម្មជាជនបរទេសដោយច្បាប់និង បទប្បញ្ញត្តិរបស់ចិន និងមិនរាប់បញ្ចូល សេវាកម្មដែលចិនចាត់ទុកថា ពាក់ព័ន្ធនឹងផលប្រយោជន៍ សន្តិសុខជាតិរបស់ខ្លួន។ | (១) | មិនសន្យា | (១) | មិនសន្យា | |
| | (២) | ពុំមានការរឹតត្បិត | (២) | ពុំមានការរឹតត្បិត | |
| | (៣) | ក្រុមហ៊ុនបុគ្រសម្ព័ន្ធកម្មសិទ្ធិទាំងស្រុងពីបរទេសត្រូវបានអនុញ្ញាត។ | (៣) | ពុំមានការរឹតត្បិត | |
| | (៤) | មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (៤) | មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | | | |
|---|---|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | | | |
| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | | ការសន្យាបន្ថែម |
| (K) សេវាកម្មជ្រើសរើស និង ផ្គត់ផ្គង់បុគ្គលិក (CPC ៨៧២, មិនរាប់បញ្ចូល លើ CPC ៨៧២០៩) | (១)<br>(២)<br>(៣)<br><br><br><br><br>(៤) | មិនសន្យា<br>មិនសន្យា<br>មានតែសហគ្រាសវិនិយោគដោយផ្នែករបស់បរទេស ដែលមានកម្មសិទ្ធិភាគហ៊ុនបរទេសភាគច្រើនតែប៉ុណ្ណោះ ត្រូវបានអនុញ្ញាត។ ការធ្វើតេស្ត តម្រូវការសេដ្ឋកិច្ច ត្រូវបានអនុវត្ត។<br><br>មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (១)<br>(២)<br>(៣)<br><br><br><br><br>(៤) | មិនសន្យា<br>មិនសន្យា<br>មិនសន្យា<br><br><br><br><br>មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |
| (m) សេវាកម្មប្រឹក្សាបច្ចេកទេសវិទ្យាសាស្ត្រពាក់ព័ន្ធ (CPC ៨៦៧៥)<br>- ភូគព្ភសាស្ត្រ, ភូគព្ភរូបវន្ត (មិនរាប់បញ្ចូលសេវាកម្មទំនាញផែនដីនិងម៉ាញេទិកក្នុងតំបន់) និងសេវាកម្មវិទ្យាសាស្ត្ររុករក (prospecting) ផ្សេងទៀត (CPC ៨៦៧៥១)<br>- សេវាកម្មអង្កេតនិងវាស់វែងក្រោមផ្ទៃដី (CPC ៨៦៧៥២) | (១)<br>(២)<br>(៣)<br><br><br><br><br><br>(៤) | ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត<br>សម្រាប់តែក្នុងទម្រង់នៃការសហការជាមួយដៃគូជាជនជាតិចិនលើសេវាកម្មរុករ (prospecting) និងអង្កេត (surveying) លើដែក ទង់ដែង ម៉ង់ហ្គាណែស ស្រទាប់ធ្យូងថ្មមេតាន និងឧស្ម័ន ថ្មសែល ។<br><br>មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (១)<br>(២)<br>(៣)<br><br><br><br><br><br>(៤) | ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត<br><br><br><br><br><br>មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | | | |
|---|---|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | | | |
| វិស័យ ឬ អនុវិស័យ | | ការរឹតត្បិតលើការបើកទីផ្សារ | | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
| - សេវាកម្មអណ្តូងប្រេងនៅសមុទ្រ | (១) | ពុំមានការរឹតត្បិត | (១) | ពុំមានការរឹតត្បិត | |
| | (២) | ពុំមានការរឹតត្បិត | (២) | ពុំមានការរឹតត្បិត | |
| | (៣) | សម្រាប់តែក្នុងទម្រង់នៃការធ្វើអាជីវកម្មប្រេងនៅក្នុងកិច្ចសហប្រតិបត្តិការជាមួយសាជីវកម្មប្រេងជាតិចិន (CNPC) ឬសាជីវកម្មចិនប៉េត្រូគីមី។ (SINOPEC) នៅក្នុងតំបន់ដែលត្រូវបានអនុម័តដោយរដ្ឋាភិបាលចិន។ ដើម្បីអនុវត្តកិច្ចសន្យាប្រេងឥន្ទនៈអ្នកផ្គត់ផ្គង់សេវាកម្មបរទេសត្រូវបង្កើតសាខា ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬការិយាល័យតំណាងនៅក្នុងដែនដីនៃសាធារណរដ្ឋប្រជាមានិតចិន និងឆ្លងកាត់បែបបទចុះបញ្ជីស្របច្បាប់។ ទីតាំងនៃការិយាល័យដែលបានរៀបរាប់ខាងលើត្រូវកំណត់តាមរយៈការពិគ្រោះយោបល់ជាមួយ CNPC ឬ SINOPEC ។ អ្នកផ្គត់ផ្គង់សេវាកម្មបរទេសត្រូវបើកគណនីធនាគាររបស់ខ្លួនជាមួយធនាគារដែលត្រូវបានអនុម័តដោយអាជ្ញាធរចិនដើម្បីធ្វើអាជីវកម្មប្តូរប្រាក់បរទេសនៅក្នុងដែនដីប្រទេសចិន។ | (៣) | អ្នកផ្គត់ផ្គង់សេវាកម្មបរទេសត្រូវផ្តល់ជូន CNPC ឬ SINOPEC ឱ្យបានត្រឹមត្រូវនិងទាន់ពេលនូវរបាយការណ៍ស្តីពីប្រតិបត្តិការប្រេងហើយត្រូវដាក់ជូនទៅ CNPC នូវទិន្នន័យនិងគំរូក៏ដូចជារបាយការណ៍បច្ចេកវិទ្យា សេដ្ឋកិច្ច គណនេយ្យ និងរដ្ឋបាលផ្សេងៗដែលទាក់ទងនឹងប្រតិបត្តិការប្រេង។ CNPC ឬ SINOPEC ត្រូវមានកម្មសិទ្ធិលើរាល់ទិន្នន័យកំណត់ត្រាគំរូ បណ្ណទូទាត់ និងព័ត៌មានដើមផ្សេងទៀតដែលទទួលបានក្នុងអំឡុងពេលអនុវត្តប្រតិបត្តិការប្រេង។ ការវិនិយោគរបស់អ្នកផ្គត់ផ្គង់សេវាកម្មបរទេសត្រូវ ធ្វើឡើងជាប្រាក់ដុល្លារអាមេរិក ឬរូបិយបណ្ណ ផ្សេងទៀត។ | |
| | (៤) | មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (៤) | មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |

# តារាងសន្យាតាមវិស័យរបស់ភាគីចិន

ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម

| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
|---|---|---|---|
| (o) សេវាកម្មសំអាតអគារ<br>(CPC ៨៧៤) | (១) មិនសន្យា*<br>(២) ពុំមានការរឹតត្បិត<br>(៣) សហគ្រាសកម្មសិទ្ធិបរទេសទាំងស្រុងត្រូវបានអនុញ្ញាត។<br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (១) មិនសន្យា*<br>(២) ពុំមានការរឹតត្បិត<br>(៣) ពុំមានការរឹតត្បិត<br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |
| (p) សេវាកម្មថតរូប<br>(CPC ៨៧៥, មិនរាប់បញ្ចូលការថតរូបពីលើអាកាសសម្រាប់ការគូសផែនទី) | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) សហគ្រាសវិនិយោគបរទេសត្រូវបានអនុញ្ញាត។<br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) ពុំមានការរឹតត្បិត<br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |
| (q) សេវាកម្មវេចខ្ចប់<br>(CPC ៨៧៦) | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) ក្រុមហ៊ុនបុត្រសម្ព័ន្ធកម្មសិទ្ធិបរទេសទាំងស្រុងត្រូវបានអនុញ្ញាត។ | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) ពុំមានការរឹតត្បិត | |

* មិនសន្យា ដោយសារកង្វះលទ្ធភាពបច្ចេកទេស

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | | | |
|---|---|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | | | |
| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | | ការសន្យាបន្ថែម |
| | (៤) | មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (៤) | មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |
| (r) ការបោះពុម្ពសម្ភារៈវេចខ្ចប់លើមូលដ្ឋានតិតកម្រៃឬកិច្ចសន្យា(កំណត់ត្រឹមការបោះពុម្ពសម្ភារៈវេចខ្ចប់ប៉ុណ្ណោះ) | (១)<br>(២)<br>(៣)<br><br><br>(៤) | មិនសន្យា<br>មិនសន្យា<br>សហគ្រាសកម្មសិទ្ធិបរទេសទាំងស្រុងត្រូវបានអនុញ្ញាត។ ការធ្វើតេស្តតម្រូវការសេដ្ឋកិច្ច ត្រូវបានអនុវត្ត ។<br>មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (១)<br>(២)<br>(៣)<br><br><br>(៤) | មិនសន្យា<br>មិនសន្យា<br>មិនសន្យា<br><br><br>មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |
| (s) សេវាកម្មរៀបចំសន្និបាត (CPC ៨៧៩០៩) | (១)<br>(២)<br>(៣)<br><br>(៤) | ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត<br>សហគ្រាសវិនិយោគដោយផ្នែករបស់បរទេសតែប៉ុណ្ណោះ ត្រូវបានអនុញ្ញាត ។<br>មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (១)<br>(២)<br>(៣)<br><br>(៤) | ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត<br><br>មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | |
|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | |
| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
| (t) សេវាកម្មបកប្រែអត្ថបទ និងបកប្រែផ្ទាល់មាត់ (CPC ៨៧៩០៥) | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) សហគ្រាសកម្មសិទ្ធិបរទេសទាំងស្រុងត្រូវបានអនុញ្ញាត។<br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) ពុំមានការរឹតត្បិត<br>(៤) គុណវុឌ្ឍិមានដូចខាងក្រោម៖ បទពិសោធន៍បីឆ្នាំក្នុងការបកប្រែអត្ថបទ ឬការបកប្រែផ្ទាល់មាត់ និងអាចប្រើប្រាស់ភាសាធ្វើការ(មួយឬច្រើន) បានយ៉ាងល្អ។ | |
| - សេវាកម្មថែទាំ និងជួសជុល (CPC ៦៣៣, ៦១១២, ៦១២២) | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) ក្រុមហ៊ុនបុត្រសម្ព័ន្ធកម្មសិទ្ធិបរទេសទាំងស្រុងត្រូវបានអនុញ្ញាត។<br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) ពុំមានការរឹតត្បិត<br>(៤) មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |
| **២. សេវាកម្មគមនាគមន៍** | | | |
| B. សេវាកម្មបញ្ញើ (CPC ៧៥១២១, លើកលែងតែសេវាកម្មបញ្ញើដែលបាន | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត | |

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | | | | |
|---|---|---|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | | | | |
| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | | ការសន្យាបន្ថែម | |
| បម្រុងទុកសម្រាប់តែអាជ្ញាធរប្រៃសណីយ៍របស់ប្រទេសចិនក្រោមច្បាប់ពាក់ព័ន្ធ នៅពេល ប្រទេសចិនចូលជាសមាជិកអង្គការ WTO កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០១) | (៣)<br><br>(៤) | ក្រុមហ៊ុនបុគ្រសម្ព័ន្ធកម្មសិទ្ធិបរទេសទាំងស្រុងត្រូវបានអនុញ្ញាត។<br><br>មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (៣)<br><br>(៤) | ពុំមានការរឹតត្បិត<br><br>មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | | |
| C. សេវាកម្មទូរគមនាគមន៍[3] សេវាកម្មតម្លៃបន្ថែម រាប់បញ្ចូលដូចជា៖<br>(h) សារអេឡិចត្រូនិក<br>(i) សារជាសម្លេង<br>(j) ការទាញយកព័ត៌មាន និងមូលដ្ឋានទិន្នន័យតាមអនឡាញ<br>(k) ការផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិក<br>(l) សេវាកម្មទូរសារ ដែលល្អប្រសើរ/មានតម្លៃបន្ថែម រួមទាំងការស្តុកទុកនិងបញ្ជូន | (១)<br>(២)<br>(៣)<br><br>(៤) | សូមមើលម៉ូត ៣<br>ពុំមានការរឹតត្បិត<br>អ្នកផ្គត់ផ្គង់សេវាកម្មបរទេសត្រូវបានអនុញ្ញាតឱ្យបង្កើតសហគ្រាសទូរគមនាគមន៍បរទេសដែលវិនិយោគដោយផ្អែកលើតម្លៃបន្ថែម ហើយការវិនិយោគបរទេសនៅក្នុងសហគ្រាសនោះមិនត្រូវលើសពី ៥០ ភាគរយឡើយ។<br><br>មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (១)<br>(២)<br>(៣)<br><br>(៤) | ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត<br><br>មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | | |

[3] ការសន្យារបស់ប្រទេសចិនត្រូវបានកំណត់ ដោយអនុលោមតាម៖ កំណត់សំគាល់សម្រាប់ការរៀបចំតារាងសន្យាសេវាកម្មទូរគមនាគមន៍មូលដ្ឋាន (S / GBT / W / 2 / REV / 1) និងការរឹតត្បិតលើការបើកទីផ្សារលើភាពអាចរកបាននៃវិសាលគម (S / GBT / W / 3) ភ្ជាប់ក្នុងឯកសារនេះ។ រាល់សេវាកម្មទូរគមនាគមន៍អន្តរជាតិត្រូវឆ្លងកាត់ច្រកចេញចូលដែលបានបង្កើតឡើងដោយមានការយល់ព្រមពីអាជ្ញាធរទូរគមនាគមន៍របស់ប្រទេសចិនដែលនឹងដើរតួជាអាជ្ញាធរនិយ័តករឯករាជ្យស្របតាមគោលការណ៍នៃកថាខណ្ឌ ៥ ក្នុងឯកសារយោង។ ការធ្វើសេរីភាវូបនីយកម្មបន្ថែមទៀតក្នុងវិស័យនេះរួមទាំងការគោរពលើកម្រិតនៃការចូលរួមសមធម៌បានអនុញ្ញាត នឹងត្រូវបានពិភាក្សានៅក្នុងកិច្ចចរចាសេវាកម្ម ក្នុងអំឡុងកិច្ចពិភាក្សាពាណិជ្ជកម្មនៅជុំថ្មី។

# តារាងសន្យាតាមវិស័យរបស់ភាគីចិន

ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម

| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | | ការសន្យាបន្ថែម |
|---|---|---|---|---|---|
| បន្ត ការស្តុកទុកនិងការទាញយក<br>(m) បរិវត្តន៍កូដនិងប្រូតូកូល<br>(n) ដំណើរការព័ត៌មាន និង/ឬ ទិន្នន័យតាមអនឡាញ (រួមមានដំណើរការប្រតិបត្តិការ) | | | | | |
| សេវាកម្មទូរគមនាគមន៍មូលដ្ឋាន<br>- សេវាកម្ម paging | (១)<br>(២)<br>(៣)<br><br><br><br><br>(៤) | សូមមើលម៉ូត ៣<br>ពុំមានការរឹតត្បិត<br>អ្នកផ្គត់ផ្គង់សេវាកម្មបរទេសត្រូវបានអនុញ្ញាតឱ្យបង្កើតសហគ្រាសវិនិយោគដោយផ្នែករបស់បរទេស ដោយមានការចូលរួមពីភាគហ៊ុនបរទេសមិនលើសពី ៥០ ភាគរយ។<br><br>មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងនៃការសន្យាទូទៅ។ | (១)<br>(២)<br>(៣)<br><br><br><br><br>(៤) | ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត<br><br><br><br><br>មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងនៃការសន្យាទូទៅ។ | ប្រទេសចិនអនុវត្តកាតព្វកិច្ចដែលមាននៅក្នុងឯកសារយោងក្នុងឯកសារភ្ជាប់ទី ១ ដែលមានភ្ជាប់ក្នុងឯកសារនេះ។ |
| សេវាកម្មទូរសព្ទចល័ត<br>- សេវាកម្មអាណាឡូក/ឌីជីថល/ទូរសព្ទដៃ<br>- សេវាកម្មទំនាក់ទំនងបុគ្គល | (១)<br>(២)<br>(៣) | សូមមើលម៉ូត ៣<br>ពុំមានការរឹតត្បិត<br>អ្នកផ្គត់ផ្គង់សេវាកម្មបរទេសត្រូវបានអនុញ្ញាតឱ្យបង្កើតសហគ្រាសវិនិយោគដោយផ្នែករបស់បរទេស ដោយមានការចូលរួមពីភាគហ៊ុនបរទេសមិនលើសពី ៤៩ ភាគរយ។ | (១)<br>(២)<br>(៣) | ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត | |

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | | | |
|---|---|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | | | |
| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | | ការសន្យាបន្ថែម |

| | | | | | |
|---|---|---|---|---|---|
| | (៤) | មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងនៃការសន្យាទូទៅ។ | (៤) | មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងនៃការសន្យាទូទៅ។ | |
| សេវាកម្មក្នុងប្រទេស<br>(a) សេវាកម្មសំឡេង<br>(b) សេវាកម្មបញ្ជូនទិន្នន័យតាមកញ្ចប់ព័ត៌មាន<br>(c) សេវាកម្មបញ្ជូនទិន្នន័យតាមសៀគ្វី<br>(f) សេវាកម្មទូរសារ<br>(g) សេវាកម្មជួលសៀគ្វីឯកជនក្នុងស្រុក<br><br>- សេវាកម្មអន្តរជាតិ<br>(a) សេវាកម្មសំឡេង<br>(b) សេវាកម្មបញ្ជូនទិន្នន័យតាមកញ្ចប់ព័ត៌មាន<br>(c) សេវាកម្មបញ្ជូនទិន្នន័យតាមសៀគ្វី<br>(f) សេវាកម្មទូរសារ<br>(g) សេវាកម្មបិទសំលេង និងទិន្នន័យអន្តរជាតិលើក្រុម | (១)<br>(២)<br><br>(៣)<br><br><br><br><br><br>(៤) | សូមមើលម៉ូត ៣<br>ពុំមានការរឹតត្បិត<br><br>អ្នកផ្គត់ផ្គង់សេវាកម្មបរទេសត្រូវបានអនុញ្ញាតឱ្យបង្កើតសហគ្រាសវិនិយោគដោយផ្នែករបស់បរទេស ដោយមានការចូលរួមពីភាគហ៊ុនបរទេសមិនលើសពី ៤៩ ភាគរយ។<br><br><br>មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងនៃការសន្យាទូទៅ។ | (១)<br>(២)<br><br>(៣)<br><br><br><br><br><br>(៤) | ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត<br><br>ពុំមានការរឹតត្បិត<br><br><br><br><br><br>មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងនៃការសន្យាទូទៅ។ | |

# តារាងសន្យាតាមវិស័យរបស់ភាគីចិន

ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម

| វិស័យ ឬ អនុវិស័យ | | ការរឹតត្បិតលើការបើកទីផ្សារ | | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
|---|---|---|---|---|---|
| អ្នកប្រើប្រាស់ (ការប្រើប្រាស់សេវាកម្មជួលសៀគ្វីឯកជនត្រូវបានអនុញ្ញាត) | | | | | |
| D. សេវាកម្មសោតទស្សន៍<br>- វីដេអូ, រួមទាំងផ្នែកទន់កម្មវិធីកំសាន្តនិង (CPC ៨៣២០២) សេវាកម្មចែកចាយ<br>- សេវាកម្មចែកចាយការថតសម្លេង | (១)<br>(២)<br>(៣)<br><br><br><br><br><br><br><br>(៤) | ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត<br>អ្នកផ្គត់ផ្គង់សេវាកម្មបរទេសត្រូវបានអនុញ្ញាតឱ្យបង្កើតសហគ្រាសវិនិយោគដោយផ្នែករបស់បរទេស ជាមួយដៃគូចិន ដើម្បីចូលរួមក្នុងការចែកចាយផលិតផលសោតទស្សន៍ ដោយមិនរាប់បញ្ចូលរូបភាពចលនា ដោយមិនរំលោភសិទ្ធិរបស់ប្រទេសចិនក្នុងការពិនិត្យមើលខ្លឹមសារនៃផលិតផលសម្លេងនិងវីដេអូ។<br><br>មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងនៃការសន្យាទូទៅ។ | (១)<br>(២)<br>(៣)<br><br><br><br><br><br><br><br>(៤) | ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត<br><br><br><br><br><br><br><br>មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងនៃការសន្យាទូទៅ។ | អនុលោមតាមការសន្យារបស់ប្រទេសចិនក្រោម GATS និងដោយមិនបំពានការអនុលោមតាម បទប្បញ្ញត្តិរបស់ប្រទេសចិនស្តីពីការគ្រប់គ្រងខ្សែភាពយន្ត ប្រទេសចិនអនុញ្ញាតឱ្យនាំចូលរូបភាពចលនាសម្រាប់បញ្ចាំងខ្សែភាពយន្ត ដោយផ្អែកលើការចែករំលែកប្រាក់ចំណូលនិងចំនួននៃការនាំចូលបែបនេះត្រូវមានចំនួន ២០ផងជារៀងរាល់ឆ្នាំ |
| សេវាកម្មរោងភាពយន្ត | (១)<br>(២)<br>(៣)<br><br><br>(៤) | ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត<br>អ្នកផ្គត់ផ្គង់សេវាកម្មកម្មសិទ្ធិបរទេសទាំងស្រុង ត្រូវបានអនុញ្ញាតឱ្យសាងសង់និង / ឬកែលម្អរោងភាពយន្ត។<br>មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងនៃការសន្យាទូទៅ។ | (១)<br>(២)<br>(៣)<br><br><br>(៤) | ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត<br><br><br>មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងនៃការសន្យាទូទៅ។ | |

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | |
|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | |
| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |

| ៣. សេវាកម្មសំណង់ និងសេវាកម្មពាក់ព័ន្ធនឹងវិស្វកម្ម | | | | | |
|---|---|---|---|---|---|
| (CPC ៥១១, ៥១២, ៥១៣[4], ៥១៤, ៥១៥, ៥១៦, ៥១៧ ៥១៨[5]) | (១)<br>(២)<br>(៣) | មិនសន្យា*<br>ពុំមានការរឹតត្បិត<br>សហគ្រាសកម្មសិទ្ធិបរទេសទាំងស្រុងត្រូវបានអនុញ្ញាត។ សហគ្រាសដែលគ្រប់គ្រងដោយបរទេសទាំងស្រុងអាចអនុវត្តគម្រោងសំណង់ ៤ ប្រភេទដូចខាងក្រោម៖<br>១.គម្រោងសាងសង់ហិរញ្ញប្បទានទាំងស្រុងដោយការវិនិយោគបរទេសនិង / ឬជំនួយឥតសំណង។<br>២.គម្រោងសាងសង់ហិរញ្ញប្បទានដោយប្រាក់កម្ចីរបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងទទួលបានតាមរយៈការដេញថ្លៃជាអន្តរជាតិយោងទៅតាមលក្ខខណ្ឌនៃប្រាក់កម្ចី។ | (១)<br>(២)<br>(៣) | មិនសន្យា*<br>ពុំមានការរឹតត្បិត<br>ពុំមានការរឹតត្បិត | សហគ្រាសសំណង់បរទេសដែលបានបង្កើតឡើងនៅក្នុងគម្រោងតំបន់ពាណិជ្ជកម្មសេរីសាកល្បង ចិន (សៀងហៃ) អាចអនុវត្តគម្រោងសាងសង់រួមគ្នារវាងជនជាតិចិននិងបរទេសនៅសៀងហៃ។ ក្នុងកាលៈទេសៈបែបនេះ សហគ្រាសសំណង់បរទេសទាំងនេះនឹងត្រូវបានលើកលែងពីតម្រូវការសមាមាត្រវិនិយោគបរទេសនៅក្នុងគម្រោងនោះ។ |

[4] រួមទាំងសេវាកម្មបូមខ្សាច់ទាក់ទងនឹងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ។

[5] ការជានាវ៉ាប់រងនៃ CPC ៥១៨ ត្រូវបានកំណត់ចំពោះសេវាកម្មជួលគ្រឿងម៉ាស៊ីន ដើម្បីសាងសង់ និង/ឬកម្ទេចដោយមានប្រតិបត្តិករបញ្ជា ដែលកាន់កាប់និងប្រើប្រាស់ដោយសហគ្រាសសំណង់បរទេសក្នុងការផ្គត់ផ្គង់សេវាកម្មរបស់ពួកគេ។

*មិនសន្យា ដោយសារកង្វះលទ្ធភាពបច្ចេកទេស

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | | | |
|---|---|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | | | |
| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | | ការសន្យាបន្ថែម |
| | | ៣. គម្រោងសាងសង់រួមគ្នារវាងជនជាតិចិន និងបរទេសជាមួយការវិនិយោគបរទេសស្មើនឹងឬច្រើនជាង ៥០ ភាគរយ ហើយ គម្រោងសាងសង់រួមគ្នាជនជាតិចិននិងបរទេសជាមួយការវិនិយោគបរទេសតិចជាង ៥០ ភាគរយ ប៉ុន្តែមានការលំបាកផ្នែកបច្ចេកទេសក្នុងការអនុវត្តដោយសហគ្រាសសំណង់ចិនតែម្នាក់ឯង។<br>៤. គម្រោងវិនិយោគសាងសង់របស់ជនជាតិចិនដែលពិបាកក្នុងការអនុវត្តដោយសហគ្រាសសំណង់ចិនតែមួយអាចត្រូវបានអនុវត្តរួមគ្នាដោយសហគ្រាសសំណង់ចិននិងបរទេសដោយមានការយល់ព្រមពីរដ្ឋាភិបាលថ្នាក់ខេត្ត | | | |
| | (៤) | មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងនៃការសន្យាទូទៅ។ | (៤) | មិនសន្យា លើកលែងតែបានបញ្ជាក់នៅក្នុងតារាងនៃការសន្យាទូទៅ។ | |
| **៤. សេវាកម្មការចែកចាយបន្ត** (ដូចមានបញ្ជាក់នៅក្នុងឯកសារភ្ជាប់លេខ២) | | | | | |
| A. សេវាភ្នាក់ងារទទួលកំរៃជើងសារ (មិនរួមបញ្ចូល អំបិល ថ្នាំជក់) | (១)<br>(២) | មិនសន្យា<br>ពុំមានការរឹតត្បិត | (១)<br>(២) | មិនសន្យា<br>ពុំមានការរឹតត្បិត | សហគ្រាសវិនិយោគបរទេស ត្រូវបានអនុញ្ញាតឱ្យចែកចាយផលិតផលរោងចក្រនៅក្នុងប្រទេសចិន ដែលរួមមាន |

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | | | | |
|---|---|---|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | | | | |
| វិស័យ ឬ អនុវិស័យ | | ការរឹតត្បិតលើការបើកទីផ្សារ | | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម | |
| B. សេវាកម្មពាណិជ្ជកម្មលក់ដុំ (មិនរួមបញ្ចូល អំបិល ថ្នាំជក់) | (៣) | សហគ្រាសកម្មសិទ្ធិបរទេសទាំងស្រុង ត្រូវបានអនុញ្ញាត។ | (៣) | ពុំមានការរឹតត្បិត | ផលិតផលដែលបានចុះក្នុងបញ្ជីអនុញ្ញាតក្នុងការបើកទីផ្សារ ឬវិស័យ/អនុវិស័យ ដែលកំណត់នៅក្នុងតារាងជួរឈរ និងផ្តល់សេវាកម្មចំណុះ ដូចមានបង្ហាញនៅក្នុងឯកសារភ្ជាប់លេខ ២។ អ្នកផ្គត់ផ្គង់សេវាកម្មបរទេស ត្រូវបានអនុញ្ញាតឱ្យផ្តល់សេវាកម្មចំណុះពាក់ព័ន្ធពេញលេញ ដែលរួមមាន សេវាកម្មបន្ទាប់ពីការលក់ ដូចមានបង្ហាញនៅក្នុងឯកសារភ្ជាប់លេខ២ ចំពោះផលិតផលដែលក្រុមហ៊ុនចែកចាយ។ |
| | (៤) | មិនសន្យា លើកលែងតែមានការបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (៤) | មិនសន្យា លើកលែងតែមានការបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |
| C. សេវាកម្មលក់រាយ (មិនរួមបញ្ចូលថ្នាំជក់) | (១) | មិនសន្យា លើកលែងតែការកម្មង់តាមរយៈសារអេឡិចត្រូនិក។ | (១) | មិនសន្យា លើកលែងតែការកម្មង់តាមរយៈសារអេឡិចត្រូនិក។ | សហគ្រាសវិនិយោគបរទេសអាចចែកចាយផលិតផលដែលផលិតក្នុងប្រទេសចិន រួមទាំងផលិតផលដែលដាក់ក្នុងតារាងជួរឈរវិស័យ / អនុវិស័យ ឬតារាងជួរឈរការបើក ទីផ្សារ និងអាចផ្តល់សេវាកម្មចំណុះ នៅក្នុងឯកសារភ្ជាប់ ២។<br><br>អ្នកផ្គត់ផ្គង់សេវាកម្មបរទេសត្រូវបានអនុញ្ញាតឱ្យផ្តល់ទាំងស្រុងនូវសេវាកម្ម |
| | (២) | ពុំមានការរឹតត្បិត | (២) | ពុំមានការរឹតត្បិត | |
| | (៣) | សហគ្រាសកម្មសិទ្ធិបរទេសទាំងស្រុង ត្រូវបានអនុញ្ញាត លើកលែងតែ៖<br>- ហាងលក់បន្តដែលលក់ផលិតផលប្រភេទ ផ្សេងគ្នា និងម៉ាកមកពីអ្នកផ្គត់ផ្គង់ច្រើនផ្សេងគ្នាដែលមានហាងលើលពី ៣០។ ចំពោះ | (៣) | ពុំមានការរឹតត្បិត | |

## តារាងសន្យាតាមវិស័យរបស់ភាគីចិន

ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម

| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
|---|---|---|---|
| | ហាងលក់បន្តច្រើនជាង៣០ ក្រុមហ៊ុនដែលមានកម្មសិទ្ធិភាគហ៊ុនបរទេសភាគច្រើន នឹងមិនត្រូវបានអនុញ្ញាតនោះទេ ប្រសិនបើហាងលក់បន្តទាំងនោះចែកចាយនូវផលិតផលដូចជា៖ សៀវភៅ កាសែត ទស្សនាវដ្តី ផលិតផលបរិក្ខារពេទ្យ ថ្នាំសម្លាប់សត្វល្អិត ខ្សែភាពយន្ត ប្រេងកាតកែច្នៃ ជីគីមី និងផលិតផលដែលមាននៅក្នុងឧបសម្ព័ន្ធ ២a នៃពិធីសារនៃការចូលអង្គការ WTO របស់ប្រទេសចិន។ ប្រតិបត្តិករហាងលក់បន្តបរទេសនឹងមានជម្រើស ក្នុងការជ្រើសរើសដៃគូណាមួយ ដែលបានរៀបចំឡើងស្របតាមច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសចិន។<br><br>(៤) មិនសន្យា លើកលែងតែមានការបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (៤) មិនសន្យា លើកលែងតែមានការបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | ចំណុះដែលពាក់ព័ន្ធ រួមមានសេវាកម្មបន្ទាប់ពីការលក់ ស្រាប់ផលិតផលដែលពួកគេចែកចាយ ដូចបានកំណត់ក្នុងឯកសារភ្ជាប់ ២។ |
| D. សេវាកម្មទិញ លក់សិទ្ធិពិសេស | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) ពុំមានការរឹតត្បិត<br><br>(៤) មិនសន្យា លើកលែងតែមានការបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) ពុំមានការរឹតត្បិត<br><br>(៤) មិនសន្យា លើកលែងតែមានការបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | |
|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | |
| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | ការសន្យាបន្ថែម |
| E. សេវាកម្មលក់ដុំ ឬលក់រាយក្រៅពីទីតាំងអចល័ត | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) ពុំមានការរឹតត្បិត[6]<br>(៤) មិនសន្យា លើកលែងតែមានការបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | (១) ពុំមានការរឹតត្បិត<br>(២) ពុំមានការរឹតត្បិត<br>(៣) ពុំមានការរឹតត្បិត<br>(៤) មិនសន្យា លើកលែងតែមានការបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ។ | |
| **៥. សេវាកម្មវិស័យអប់រំ** | | | |
| (មិនរួមបញ្ចូលសេវាកម្មពិសេសដូចជា សាលាទាហាន ប៉ូលីស នយោបាយនិងបក្សនយោបាយ)<br>A. សេវាកម្មអប់រំថ្នាក់បឋមសិក្សា (CPC ៩២១ មិនរួមបញ្ចូលវិស័យអប់រំជាកាតព្វកិច្ចថ្នាក់ជាតិ នៅក្នុង CPC ៩២១៩០)<br>B. សេវាកម្មអប់រំថ្នាក់អនុវិទ្យាល័យ (CPC ៩២២) មិនរួមបញ្ចូលវិស័យអប់រំជា | (១) មិនសន្យា<br>(២) ពុំមានការរឹតត្បិត<br>(៣) សាលាដែលវិនិយោគដោយដោយផ្អែករបស់បរទេសដែលមានភាគហ៊ុនកម្មសិទ្ធិបរទេសភាគច្រើនត្រូវបានអនុញ្ញាត<br>(៤) មិនសន្យា លើកលែងតែមានការបញ្ជាក់នៅក្នុងតារាងសន្យាទូទៅ និងការបញ្ជាក់ដូចខាងក្រោម៖ អ្នកផ្គត់ផ្គង់សេវាកម្មអប់រំបរទេសអាចចូលទៅក្នុងប្រទេសចិនដើម្បីផ្តល់សេវាកម្មអប់រំនៅពេលដែលមានការអញ្ជើញ ឬត្រូវបានជួលដោយសាលា និងស្ថាប័នអប់រំផ្សេងទៀតរបស់ប្រទេសចិន។ | (១) មិនសន្យា<br>(២) ពុំមានការរឹតត្បិត<br>(៣) មិនសន្យា<br>(៤) ត្រូវមានគុណវុឌ្ឍិដូចខាងក្រោម៖<br>-មានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រកម្រិតខ្ពស់ជាងនេះ<br>-និងមានសញ្ញាបត្រវិជ្ជាជីវៈសមរម្យជាមួយបទពិសោធន៍វិជ្ជាជីវៈ២ឆ្នាំ។ | |

6 សូមមើលកថាខណ្ឌ៣១០ នៃរបាយការណ៍ក្រុមការងារលើការចូលជាសមាជិក WTO របស់ចិន។

| តារាងសន្យាតាមវិស័យរបស់ភាគីចិន | | | | | |
|---|---|---|---|---|---|
| ម៉ូតនៃការផ្គត់ផ្គង់៖ ១) ការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់នៅបរទេស ៣) វត្តមានពាណិជ្ជកម្ម ៤) វត្តមាននៃជនជាតិដើម | | | | | |
| វិស័យ ឬ អនុវិស័យ | ការរឹតត្បិតលើការបើកទីផ្សារ | | ការរឹតត្បិតលើប្រព្រឹត្តិកម្មជាតិ | | ការសន្យាបន្ថែម |
| កាតព្វកិច្ចថ្នាក់ជាតិ នៅក្នុង CPC ៩២២១០)<br>C. សេវាកម្មអប់រំថ្នាក់ ឧត្តមសិក្សា (CPC 923)<br>D. សេវាកម្មអប់រំសម្រាប់មនុស្សពេញវ័យ (CPC 924 រួមបញ្ចូលទាំងការបណ្តុះបណ្តាលលើការព្យាបាលសម្ផស្ស ស្ប៉ា និងការចាក់ម្ជុលវិទ្យាសាស្ត្រ<br>E. សេវាកម្មអប់រំផ្សេងទៀត (CPC 929 រួមបញ្ចូលទាំងការបណ្តុះបណ្តាលក្រៅប្រព័ន្ធអប់រំ ដូចខាងក្រោម៖<br>a. ភាសាអង់គ្លេស<br>b. ការចម្អិនអាហារ<br>c. សិប្បកម្ម | | | | | |
| **៦. សេវាកម្មវិស័យបរិស្ថាន**<br>(មិនរួមបញ្ចូលការគ្រប់គ្រងគុណភាពបរិស្ថាន និងការត្រួតពិនិត្យប្រភពនៃការបំពុល) | | | | | |
